# ផលិតកម្មនិងការផ្គត់ផ្គង់ពូជដំណាំ

ការធ្វើពិពិធកម្មប្រព័ន្ធផ្គត់ផ្គង់គ្រាប់ពូជស្រូវ គឺជាអាទិភាពខ្ពស់មួយ ដើម្បីបង្កើតនូវទីផ្សារប្រកួតប្រជែង និងបង្កើនជម្រើសនៃប្រភេទពូជសម្រាប់កសិករ និងអ្នកផ្គត់ផ្គង់

តាមកិច្ចសន្យា (Contract Farming) សម្រាប់ផលិតកម្មពូជដំណាំ នឹងត្រូវលើកទឹកចិត្តឱ្យបានខ្លាំងក្លា ព្រោះវាជាយន្តការមួយក្នុងការជំរុញការអភិវឌ្ឍន៍វិស័យផលិតកម្មពូជដំណាំ

គាំទ្រពេញទំហឹងចំពោះការចូលរួមពីសំណាក់រោងម៉ាស៊ីនកិនស្រូវ និងសមាគមម៉ាស៊ីនកិនស្រូវនៅក្នុងសង្វាក់ផ្គត់ផ្គង់គ្រាប់ពូជ ដើម្បីលើកកម្ពស់ផលិតកម្មប្រភេទពូជដែលមានតម្រូវការច្រើនជាងគេ និងកាត់បន្ថយភាគរយនៃអង្ករចម្រុះនៅលើទីផ្សារ

- ឯកសារគម្រោងផលិតកម្មពូជដំណាំប្រកបដោយជោគជ័យ
- ការរៀបចំផែនការផលិតកម្មពូជស្រូវ
- ផែនការសកម្មភាពសម្រាប់ជម្រុញការនាំចេញអង្ករ
- ការលើកកម្ពស់ផ្នែកអ្នកផលិតពូជជាផ្លូវការ

# ផ្នែកទី ៨
# ការនាំចូលគ្រាប់ពូជដំណាំ

**ពូជនាំចូល**

- ធ្វើពិពិធកម្មនៃប្រភេទពូជសម្រាប់ធ្វើឲ្យប្រសើរឡើងផលិតកម្មនិងទីផ្សារ
- ធ្វើឲ្យមានភាពងាយដល់ដំណើរការនាំចូល
- បំពេញតាមលក្ខខណ្ឌភោត្តគាមអនាម័យនិងស្តង់ដាពូជដំណាំ។

**ពូជនាំចេញ**

- ឱកាស សម្រាប់ការនាំចេញពូជដំណាំក្នុងតំបន់
- ការបង្កើតនៃមន្ទីរពិសោធនិសម្រាប់ធ្វើតេស្តសាកល្បងពីគុណភាពពូជដំណាំ។

# ផ្នែកទី ៩
# ពូជបន្លែ

**ពូជនាំចូល**

- មានស្លាកសញ្ញាវេចខ្ចប់ត្រឹមត្រូវជាអក្សរខ្មែរ
- ស្តង់ដាគុណភាពគ្រាប់ពូជដំណាំ
- បោះពុម្ពបញ្ជីព័ត៌មាននៃពូជដំណាំនាំចូលជាអក្សរខ្មែរ
- លក់ចែកចាយលើទីផ្សារ ត្រូវស្ថិតក្នុងសំបកវេចខ្ចប់ ដើមត្រឹមត្រូវ

**ការវេចខ្ចប់ក្នុងតំបន់នៃពូជនាំចូល**

រាល់ការវេចខ្ចប់សារជាថ្មីនៅក្នុងស្រុកនូវរាល់ពូជដំណាំនាំចូល ដែលពុំទាន់ធ្វើការវេចខ្ចប់ ត្រូវផ្តល់ព័ត៌មានដល់អគ្គនាយកដ្ឋានកសិកម្ម ដើម្បីធ្វើការត្រួតពិនិត្យគុណភាព និងលក្ខណៈបច្ចេកទេសនៃការវេចខ្ចប់ សំដៅធានាបាននូវគុណភាពត្រឹមត្រូវស្របតាមស្តង់ដារបច្ចេកទេស។